**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងស្តីអំពីនីតិវិធីទូទាត់ជូនកម្មករ និយោជិត

**រវាង**

**ក្រុមហ៊ុន វីតូរីយ៉ា អង្គរ ខមភេនី លីមីធីត**

**និង**

**តំណាងបុគ្គលិក និយោជិតនៃក្រុមហ៊ុន វីតូរីយ៉ា អង្គរ ខមភេនី លីមីធីត**

នាថ្ងៃទី.២៩.ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង០៨និង៣០នាទីព្រឹក នៅសណ្ឋាគារ វីតូរីយ៉ា អង្គរ រីសត & ស្ប៉ា (Victoria Angkor Resort & Spa) ដែលវិនិយោគដោយក្រុមហ៊ុន វីតូរីយ៉ា អង្គរ ខមភេនី លីមីធីត (Victoria Angkor Company Limited) មានបើកកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងតំណាងបុគ្គលិក និយោ ជិតនៃក្រុមហ៊ុន ដោយក្រុមហ៊ុនបានធ្វើការជូនដំណឹងដល់បុគ្គលិក និយោជិតទាំងអស់អំពីស្ថានភាពផលប៉ះពាល់ យ៉ាងធ្ងន់ធ្ងរមកលើដំណើរការសេវាកម្មរបស់ក្រុមហ៊ុន (គ្មានអតិថិជន ឬសឹងគ្មានអតិថិជន) ព្រោះតែវិបត្តិនៃជំងឺ កូវីដ-១៩(COVID-19) ។

បន្ទាប់ពីពិភាក្សាគ្នាយ៉ាងល្អិតល្អន់ក្នុងអង្គប្រជុំប្រកបដោយបរិយាកាសស្និទ្ធស្នាល និងក្នុងស្មារតីទទួលខុសត្រូវ ខ្ពស់នោះរួចមក ភាគីទាំងពីរបានសម្រេចព្រមព្រៀងគ្នាដូចខាងក្រោម ៖

១-ព្យួរកិច្ចសន្យាការងាររបស់បុគ្គលិក និយោជិត ចំនួន.២៤ .នាក់ បម្រើការងារនៅផ្នែក ម្ហូបអាហារនិងភេសជ្ជៈ(១នាក់) វិស្វករ (០១នាក់) ស្ប៉ា(០៥នាក់)ចង្ក្រាន(៧នាក់) គេហកិច្ច(៦នាក់) ហិរញ្ញវត្ថុ(៤នាក់) រយៈពេល០២(ពីរ)ខែ គិតចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០ ។

២-ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះ បុគ្គលិក និយោជិតម្នាក់ៗនឹងទទួលបានប្រាក់ឧបត្ថម្ភពី ក្រុមហ៊ុនចំនួន៣០(សាមសិប)ដុល្លារអាមេរិកក្នុង១ខែ ។

៣-ក្រុមហ៊ុននឹងបំពេញបែបបទស្នើសុំប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលជូនបុគ្គលិក និយោជិតនៅក្នុងអំឡុងពេល នៃការព្យួរកិច្ចសន្យាការងារនេះតាមនីតិវិធី ។

៤-ក្នុងករណីក្រុមហ៊ុនមានដំណើរការសេវាកម្មល្អប្រសើរឡើងវិញ គឺក្រុមហ៊ុននឹងជូនដំណឹងដល់បុគ្គលិក និយោ ជិតឲ្យវិលត្រឡប់មកបំពេញការងារវិញដោយរក្សាមុខតំណែង តួនាទី និងប្រាក់ឈ្នួលជាធម្មតា ។

*ធ្វើនៅសៀមរាប, ថ្ងៃទី ៣០ .ខែឧសភា ឆ្នាំ២០២០*

តំណាងប្រតិភូបុគ្គលិក

**សួន កុឡាប** 30/May/20

នាយកគ្រប់គ្រងក្រុមហ៊ុន

30/5/20

Jancloes Benoit